# រាជបណ្ឌិត្យសភាកម្ពុជា
# វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម

## អត្ថបទស្រាវជ្រាវ

## បញ្ហាប្រឈមនិងឱកាសសម្រាប់សហគ្រាសតូចនិងមធ្យមនៅកម្ពុជា៖ ករណីសិក្សាហាងកាហ្វេក្នុងស្រុកចំនួន៥ក្នុងក្រុងភ្នំពេញ







លី តុង ឈឿន សារេន និង ផុន កាសិកា

ឆ្នាំ២០២០

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជបណ្ឌិត្យសភាកម្ពុជា**
**វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម**

# បញ្ហាប្រឈម និងឱកាសសម្រាប់សហគ្រាសតូចនិងមធ្យមនៅកម្ពុជា ៖ ករណីសិក្សាហាងកាហ្វេក្នុងស្រុកចំនួន៥ ក្នុងក្រុងភ្នំពេញ

**(Challenges and Opportunities of SME in Cambodia: A Case Study of Five Local Coffee Brands in Phnom Penh)**


លី តុង
រាជបណ្ឌិត្យសភាកម្ពុជា
Email: lytongcambodia2013@gmail.com

ឈឿន សាវន
រាជបណ្ឌិត្យសភាកម្ពុជា
Email: savornui2018@gmail.com

បណ្ឌិត ផុន កសិកា
រាជបណ្ឌិត្យសភាកម្ពុជា
Email: kaseka1975@yahoo.com



**មូលន័យសង្ខេប**

*ទំនោរនៃការទទួលទានកាហ្វេនៅក្នុងប្រទេសកម្ពុជា ជាពិសេសក្នុងទីក្រុងភ្នំពេញ មានការកើនឡើងគួរឱ្យកត់សំគាល់ក្នុងរយៈពេលប៉ុន្មានឆ្នាំនេះ នឹងបានជម្រុញឱ្យមានការវិនិយោគកាន់តែច្រើនឡើងនៃអាជីវកម្មកាហ្វេបែបទំនើប ដែលក្នុងនោះអាជីវកម្មទាំងនេះ ក៏បានបង្កើតនូវឱកាសការងារ និងការប្រកួតប្រជែងរវាងអាជីវកម្មហាងកាហ្វេម្ចាស់ស្រុក និងហាងកាហ្វេម៉ាកផលិតផលបរទេសផងដែរ។ ការសិក្សានេះមានវត្ថុបំណងចម្បងគឺ (១) សិក្សាពីបញ្ហាប្រឈមដែលហាងកាហ្វេក្នុងស្រុកបាននឹងកំពុងជួបប្រទះ ក្នុងបរិបទនៃការប្រកួតប្រជែងជាមួយនឹងហាងកាហ្វេម៉ាកផលិតផលបរទេស និង (២) សិក្សាពីឱកាសអាជីវកម្មដែលហាងកាហ្វេក្នុងស្រុកអាចបង្កើតបានក្នុងបរិបទនៃការប្រកួតប្រជែងនេះ។ ការសិក្សានេះប្រើវិធីសាស្ត្រស្រាវជ្រាវបែបចម្រុះ (Mixed Research Methodology) ទៅលើសំណាកគម្រូដែលជាស្ថាបនិក ឬអ្នកគ្រប់គ្រងអាជីវកម្មហាងកាហ្វេក្នុងស្រុកចំនួន ៥រូប និងបុគ្គលិកបម្រើការងារក្នុងហាងកាហ្វេចំនួន ២៤រូប។ លទ្ធផល*

*បង្ហាញថា ឱកាសអាជីវកម្មហាងកាហ្វេនៅកម្ពុជា នៅតែមានការកើនឡើងជានិច្ច បើទោះបីជាអាជីវកម្មទាំងនោះ អាចនឹងជួបប្រទះនូវបញ្ហាប្រឈមមួយចំនួនដូចជា៖ ប្រភពដើមទុន ការពង្រឹងសេវាកម្ម សេដ្ឋកិច្ច និងគុណភាពកាហ្វេ។ អាជីវកម្មកាហ្វេនេះ បានចូលរួមបង្កើតការងារសម្រាប់យុវជនកម្ពុជាទាំងអ្នករស់នៅរាជធានីភ្នំពេញ ក៏ដូចជាអ្នកដែលមានប្រភពមកពីខេត្តនានាផ្សេងៗ។ ក្រៅពីឱកាសការងារ បុគ្គលិកទាំងនោះ ថែមទាំងអាចពង្រឹងសេដ្ឋកិច្ចគ្រួសារ និងពង្រីកឱកាសសម្រាប់ការសិក្សាបន្ថែមផងដែរ។*

**ពាក្យគន្លឹះ៖** បញ្ហាប្រឈម ឱកាសអាជីវកម្ម ឱកាសការងារ សហគ្រាសខ្នាតតូចនិងមធ្យម ហាងកាហ្វេក្នុងស្រុក និងហាងកាហ្វេម៉ាកផលិតផលបរទេស

# ១. សេចក្តីផ្តើម

កម្ពុជាក្នុងពេលបច្ចុប្បន្នបានប្រើប្រាស់ប្រព័ន្ធសេដ្ឋកិច្ចទីផ្សារបើកចំហ ហើយគេសង្កេតឃើញថាក្នុងអំឡុងពេលមួយទសវត្សចុងក្រោយនេះ កំណើនសេដ្ឋកិច្ចកម្ពុជាមានការកើនឡើងយ៉ាងខ្លាំង។ តាមទិន្នន័យរបស់រដ្ឋាភិបាល ក៏ដូចជាធនាគារពិភពលោក និងធនាគារអភិវឌ្ឍអាស៊ីបានបង្ហាញថាប្រទេសកម្ពុជាទទួលបានកំណើនសេដ្ឋកិច្ចប្រចាំឆ្នាំប្រមាណ ៧.៧% ក្នុងចន្លោះឆ្នាំ១៩៩៥ និងឆ្នាំ ២០១៨ ហើយអត្រានេះ បានធ្វើឱ្យកម្ពុជាក្លាយទៅជាប្រទេសមួយដែលមានកំណើនសេដ្ឋកិច្ចលឿនជាងគេក្នុងពិភពលោក។ ក្នុងឆ្នាំ២០១៩កន្លងទៅ កម្ពុជាមានផលិតផលក្នុងស្រុកសរុប (GDP) ជាង 27.089 ប៊ីលានដុល្លា (The World Bank Data, 2020)។ បើទោះបីជាមានកំណើនខ្ពស់យ៉ាងណាក៏ដោយ ចំណូលសរុបរបស់ប្រជាពលរដ្ឋម្នាក់ៗក្នុងមួយឆ្នាំ នៅមានកម្រិតទាបនៅឡើយ បើប្រៀបធៀបជាមួយនឹងប្រទេសជិតខាង។

ជាមួយនឹងកិច្ចប្រឹងប្រែងដ៏សកម្មនេះ កម្ពុជាបានប្រែក្លាយខ្លួនទៅជាប្រទេសមានប្រាក់ចំណូលទាបកម្រិតមធ្យមក្នុងឆ្នាំ២០១៥ និងមានមហិច្ឆតាក្លាយខ្លួនទៅជាប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ ២០៣០។ គេសង្កេតឃើញថា ឧស្សាហកម្មចម្បងចំនួនពីរ៖ (១) ឧស្សាហកម្មកាត់ដេរ និង (២) វិស័យទេសចរណ៍ បានដើរតួយ៉ាងសំខាន់ក្នុងការជម្រុញកំណើនសេដ្ឋកិច្ចក្នុងប្រទេសនេះ ចំណែកឯកសិកម្មនៅតែដើរតួជាចម្បងសម្រាប់ប្រជាពលរដ្ឋដែលរស់នៅតាមទីជនបទ (Weggel & Oskar, 2006)។ ជាមួយនឹងវិស័យធំៗដែលជម្រុញសេដ្ឋកិច្ចជាតិទាំងនេះ សហគ្រាសតូចនិងមធ្យមបានដើរតួជាចម្បងក្នុងការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ចជាតិទាំងមូល ដោយគ្រឹះស្ថានទាំងនេះបានរួមចំណែកក្នុងការបង្កើតការងារប្រមាណ ៤០%-៥០% នៃការងារសរុបក្នុងស្រុក (Samantha Fuentes, 2018)។ យើងសង្កេតឃើញថា មានកត្តាជាច្រើនបានរួមចំណែកក្នុងការថែរក្សាកំណើន

សេដ្ឋកិច្ចកម្ពុជាមានដូចជា កត្តាសន្តិភាព ការវិនិយោគទុនបរទេស ព្រមទាំងការរីកចម្រើននៃវិស័យធំៗ ខាងលើជាដើម។

សហគ្រាសតូចនិងមធ្យម (SMEs) ត្រូវបានគេចាត់ទុកថាជាកម្លាំងចលករុញច្រានកំណើន និងការអភិវឌ្ឍសេដ្ឋកិច្ចជាតិដ៏សំខាន់ ជាពិសេសក្នុងប្រទេសកំពុងអភិវឌ្ឍ (Keskġn, Hidayet et al, 2020)។ បើយើងក្រឡេកមើលក្នុងបរិបទសកល សហគ្រាសតូចនិងមធ្យមបានចូលរួមចំណែកបង្កើតនូវអាជីវកម្មប្រមាណ ៩០% នៃអាជីវកម្មទាំងអស់ និងបង្កើតការងារបានលើសពី ៥០% នៃការងារសកម្មទូទាំងពិភពលោក។ ដោយឡែកនៅក្នុងប្រទេសកម្ពុជា សហគ្រាសតូចនិងមធ្យមបានរួមចំណែកយ៉ាងខ្លាំងទៅលើការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គម ដោយបានដើរតួក្នុងការបង្កើតការងារ បង្កើនប្រាក់ចំណូលដល់ប្រជាពលរដ្ឋដែលមានជីវភាពក្រីក្រ និងងាយរងគ្រោះ ព្រមទាំងបានជម្រុញនូវកំណើនសេដ្ឋកិច្ច រក្សាស្ថេរភាពសង្គម និងរួមចំណែកក្នុងការលើកតម្កើងនូវវិស័យឯកជនផងដែរ។ លើសពីនេះទៅទៀត បើតាមស្ថិតិរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ កាលពីឆ្នាំ ២០១៨ បានបង្ហាញថា វិស័យនេះ បានរួមចំណែកបង្កើតការងារប្រមាណ ៧០% នៃការងារសកម្ម និងចូលរួមប្រមាណជិត ៦០% នៃផលទុនសរុបរបស់ជាតិ (Sok Chan, 2020)។

ឯកឧត្តម ហេង សុខគង់ រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ (អតីត ក្រសួងឧស្សាហកម្ម និងសិប្បកម្ម) បានធ្វើការគូសបញ្ជាក់ថា នៅក្នុងប្រទេសកម្ពុជា មានក្រុមហ៊ុនប្រមាណជា ៥១០,០០០ ក្រុមហ៊ុនដែលបានចុះបញ្ជីការត្រឹមត្រូវ ហើយក្នុងចំណោមនោះ ៩០% គឺជាប្រភេទសហគ្រាសតូច និងមធ្យម (Hin Pisei, 2019)។ ក្នុងបរិបទនេះ គេសង្កេតឃើញថា សហគ្រាសនៅក្នុងប្រទេសកម្ពុជាត្រូវបានបែងចែកជាបួនប្រភេទ ទៅតាមចំនួនបុគ្គលិកបម្រើការងារ និងទំហំនៃដើមទុនអាជីវកម្ម។ ក្នុងចំណោមសហគ្រាសទាំងនេះ សហគ្រាសប្រភេទមីក្រូ (Micro Enterprise) បង្កើតឡើង និងប្រកបអាជីវកម្មពុំមានលក្ខណៈជាប្រព័ន្ធត្រឹមត្រូវនោះទេ ក៏ប៉ុន្តែវាបានរួមចំណែកច្រើនជាងគេក្នុងចំណោមប្រភេទសហគ្រាសទាំងអស់។ ការបែងចែកប្រភេទសហគ្រាសក្នុងប្រទេសកម្ពុជាត្រូវបានកំណត់ដូចក្នុងតារាងខាងក្រោម៖

*តារាងទី 1៖ ការបែងចែកប្រភេទសហគ្រាសនៅកម្ពុជា*

| ចំណាត់ថ្នាក់សហគ្រាស | និយមន័យរបស់រដ្ឋាភិបាល | |
|---|---|---|
| | ចំនួនបុគ្គលិក/កម្មករ | ទ្រព្យសកម្ម |
| សហគ្រាសប្រភេទមីក្រូ (Micro) | ១០នាក់ | តិចជាង ៥០,០០០$ |
| សហគ្រាសខ្នាតតូច | ១១-៥០នាក់ | ៥០,០០០$-២៥០,០០០$ |

| | | |
|---|---|---|
| សហគ្រាសខ្នាតមធ្យម | ៥១-១០០នាក់ | ២៥០,០០០$-៥០០,០០០$ |
| សហគ្រាសខ្នាតធំ | លើសពី១០០នាក់ | លើសពី ៥០០,០០០$ |

ប្រភព៖ SME Development Framework (29 July 2005)

នៅក្នុងប្រទេសកម្ពុជា អាជីវកម្មខ្នាតតូចនិងមធ្យមនេះ ត្រូវបានបែងចែកជា៣ប្រភេទគឺ៖

- ប្រភេទផលិតកម្ម មានដូចជា អាជីវកម្មកែច្នៃផលិតផលកសិកម្មជាដើម
- ប្រភេទអាជីវកម្មផ្តល់សេវាកម្ម
- ប្រភេទអាជីវកម្មពាណិជ្ជកម្ម រាប់បញ្ចូលទាំងអាជីវកម្មលក់ដុំ និងរាយគ្រប់ប្រភេទ

ជាមួយនឹងការរីកចម្រើនក្នុងវិស័យអាជីវកម្ម និងឧស្សាហកម្មខ្នាតតូចនិងមធ្យមនេះ យើងសង្កេតឃើញថាអាជីវកម្មហាងកាហ្វេដែលជាផ្នែកមួយនៃសហគ្រាសតូចនិងមធ្យមដែរនោះ ក៏មានរីកលូតលាស់ខ្លាំងគួរឱ្យកត់សម្គាល់ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។ ជាការពិត ទម្លាប់នៃការទទួលទានកាហ្វេ បានកើតមានក្នុងសង្គមកម្ពុជាជាយូរមកហើយ ជាពិសេសក្នុងចំណោមប្រជាពលរដ្ឋរស់នៅក្នុងរាជធានីភ្នំពេញនិងតាមទីរួមខេត្តនានា ក៏ប៉ុន្តែការទទួលទានកាហ្វេតាមបែបប្រពៃណី ច្រើនស្ថិតក្នុងទម្រង់តាមផ្ទះរៀងៗខ្លួន ឬតាមតូប និងហាងអាហារតូចៗតាមដងផ្លូវប៉ុណ្ណោះ។ ទើបតែឈានមកដល់រយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ទម្លាប់នៃការទទួលទានកាហ្វេកើតមានយ៉ាងខ្លាំង មិនត្រឹមតែក្នុងចំណោមមន្ត្រីរាជការ បុគ្គលិកក្រុមហ៊ុនឯកជន អ្នករត់តាក់ស៊ី ម៉ូតូឌុបនោះទេ តែទម្លាប់នេះក៏បានកើតមានក្នុងចំណោមយុវជនក្មេងៗដែលជាសិស្សសាលា ឬនិស្សិតផងដែរ។ ដោយសារតែទំនោរនៃការចូលចិត្តទទួលទានកាហ្វេបែបនេះ ទើបកាលពីដើមឆ្នាំ២០២០កន្លងទៅនេះ គេបានប្រសិទ្ធិនាមទីក្រុងភ្នំពេញថា "ទីក្រុងកាហ្វេ" ទៀតផង។

ទំនោរនៃការទទួលទានអាហារ បានជម្រុញឱ្យអាជីវកម្មកាហ្វេមានការអភិវឌ្ឍ និងប្រែមុខមាត់ថ្មីជាបន្តបន្ទាប់ ដោយការប្រែរូបរាងពីការលក់ដូរតាមតូបតូចៗតាមដងផ្លូវ មកជាហាងកាហ្វេធំៗដែលមានអនាម័យខ្ពស់ និងមានការរៀបចំបែបទំនើបៗជាដើម។ ហាងកាហ្វេទាំងនោះបានដើរតួមិនត្រឹមតែជាទីតាំងសម្រាប់ប្រកបអាជីវកម្មប៉ុណ្ណោះទេ ប៉ុន្តែមួយចំនួន ក៏បានក្លាយទៅជាការិយាល័យធ្វើការ ទីជំនួបពិភាក្សាការងារ កន្លែងរៀបចំកម្មវិធីខួបកំណើត ព្រមទាំងជាទីតាំងដើម្បីធ្វើការរៀនសូត្ររបស់យុវជនកម្ពុជាផងដែរ (Phoung Vantha, 2019)។ អាជីវកម្មកាហ្វេទាំងនោះ ដែលរួមមានទាំងម៉ាកកាហ្វេក្នុងស្រុក និងហាងកាហ្វេម៉ាកបរទេស ដែលបាននឹងកំពុងឈរជើងប្រកួតប្រជែងក្នុងទីផ្សារកម្ពុជា បានធ្វើឱ្យឱកាសរសម្រាប់អាជីវកម្មកាហ្វេនេះកាន់តែមមាញឹកខ្លាំងជាងមុន (Sok Chan, 2020;

Phoung Vantha, 2019)។ ខាងក្រោមនេះជាទិន្នន័យហាងកាហ្វេល្បីៗមួយចំនួន រាប់បញ្ចូលទាំងម៉ាកកាហ្វេក្នុងស្រុក និងម៉ាកកាហ្វេបរទេសផងដែរ ដែលកំពុងមានវត្តមានព្រះរាជាណាចក្រកម្ពុជា។

*តារាងទី 2៖ ហាងកាហ្វេម្ចាស់ស្រុក និងបរទេសល្បីៗមួយចំនួនក្នុងប្រទេសកម្ពុជា*

| ហាងកាហ្វេម្ចាស់ស្រុក | | ហាងកាហ្វេម៉ាកបរទេស | ប្រភព |
|---|---|---|---|
| កាហ្វេប្រោន | | Amazon Coffee | ថៃ |
| ផាកកាហ្វេ | | Starbuck Coffee | អាមេរិក |
| មីស្ទ័រប្រ៊ូវ | | KOI Café | តៃវ៉ាន់ |
| សារមន្ទីរកាហ្វេ | | | |

# ២. វិធីសាស្ត្រស្រាវជ្រាវ

ការសិក្សានេះមានវត្ថុបំណងចម្បងចំនួនពីរគឺ (១) សិក្សាពីបញ្ហាប្រឈមដែលហាងកាហ្វេក្នុងស្រុក (Local Coffee Shop) បាននឹងកំពុងជួបប្រទះ ក្នុងបរិបទនៃការប្រកួតប្រជែងផ្នែកអាជីវកម្មជាមួយនឹងហាងកាហ្វេម៉ាកផលិតផលបរទេស (Foreign Coffee Shop) និង (២) សិក្សាពីឱកាសអាជីវកម្មដែលហាងកាហ្វេក្នុងស្រុក អាចបង្កើតបានក្នុងបរិបទនៃការប្រកួតប្រជែងជាមួយម៉ាកផលិតផលបរទេស (Foreign Coffee Brand)។ ការសិក្សានេះក៏នឹងផ្ដោតផងដែរ លើការរួមចំណែករបស់អាជីវកម្មកាហ្វេ ក្នុងការបង្កើតការងារដល់យុវជនកម្ពុជា ព្រមទាំងឱកាសរបស់ពួកគេក្នុងការបន្តការសិក្សាបន្ថែមទៀតជាដើម។ ការសិក្សានេះប្រើវិធីសាស្ត្រស្រាវជ្រាវបែបចម្រុះ (Mixed Research Methodology) ដែលក្នុងនោះ បញ្ជីសំណួរទម្រង់ពិភាក្សាត្រូវបានប្រើប្រាស់ ដើម្បីប្រមូលទិន្នន័យពីក្រុមគោលដៅដែលជាម្ចាស់ ឬថ្នាក់ដឹកនាំហាងកាហ្វេក្នុងស្រុក ចំណែកឯកម្រងសំណួរបែបស្ទង់មតិ (Survey Questionnaire) ត្រូវបានប្រើប្រាស់ដើម្បីប្រមូលទិន្នន័យពីបុគ្គលិកបម្រើការងារក្នុងហាងកាហ្វេដែលចូលរួមក្នុងការសិក្សានេះ។ ក្រុមគោលដៅដែលចូលរួមក្នុងការសិក្សានេះមាន ម្ចាស់និងអ្នកគ្រប់គ្រងហាងកាហ្វេចំនួន៥រូប ព្រមទាំងបុគ្គលិកបម្រើការងារក្នុងហាងកាហ្វេទាំងនោះចំនួន២៤រូប ដែលក្នុងនោះមាន ១៣នាក់ជាបុគ្គលិកភេទស្រី។ ទិន្នន័យដែលបានមកពីវិធីសាស្ត្របែបគុណភាព ត្រូវបានវិភាគតាមការវិភាគខ្លឹមសារ (Content Analysis) ដើម្បីកំណត់ទីសេចក្ដី សម្រាប់បន្សុីជាមួយនឹងវត្ថុបំណងនៃការស្រាវជ្រាវ។ ម្យ៉ាងទៀត ទិន្នន័យដែលបានមកពីវិធីសាស្ត្របែបបរិមាណ ត្រូវបានវិភាគដោយប្រើប្រាស់កម្មវិធីវិភាគទិន្នន័យ SPSS Version 25 ដោយប្រើប្រាស់ស្ថិតិពណ៌នា (Descriptive Statistics) ដើម្បីពន្យល់បន្ថែមទៅលើលទ្ធផលដែលបានមកពីការវិភាគទិន្នន័យគុណភាព។

# ៣. លទ្ធផលនិងការពិភាក្សា

## ៣.១. ស្ថានភាពទូទៅនៃអាជីវកម្មកាហ្វេ

គេសង្កេតឃើញថា ស្ថានភាពទូទៅអាជីវកម្មកាហ្វេនៅក្នុងប្រទេសកម្ពុជា ជាពិសេសក្នុងទីក្រុងភ្នំពេញមានភាពរីកលូតលាស់ច្រើន មិនថាជាប្រភេទហាងកាហ្វេខ្នាតតូច ខ្នាតមធ្យម ឬហាងកាហ្វេខ្នាតធំ ដែលមានបុគ្គលិកច្រើននោះទេ។ ក៏ប៉ុន្តែអាជីវកម្មនេះ ក៏ប្រឈមនឹងការប្រកួតប្រជែងខ្ពស់ដូចគ្នា ដែលជាក់ស្តែង មានហាងកាហ្វេជាច្រើនចាប់ផ្តើមបើករកស៊ី ទាំងប្រភេទក្នុងស្រុក និងម៉ាកសញ្ញាក្រៅស្រុកជាដើម។ ផ្អែកលើទស្សនៈរបស់ថ្នាក់ដឹកនាំ និងម្ចាស់ហាងកាហ្វេដែលបានចូលរួមក្នុងការស្រាវជ្រាវនេះ បានបង្ហាញថា ស្ថិតក្នុងបរិបទនៃការប្រកួតប្រជែងកាន់តែខ្លាំង ការបើកអាជីវកម្មកាហ្វេដោយប្រើដើមទុនតិចតួច ឬក្នុងទម្រង់តូចៗ គឺមានការពិបាកក្នុងការឈរជើងនៅក្នុងទីផ្សារ ដោយសារតែចំណូលចិត្តអតិថិជន មានការប្រែប្រួល និងទំនោរទៅរកអ្វីដែលថ្មី និងទំនើប។ បើទោះបីជាមានការប្រកួតប្រជែងខ្លាំងយ៉ាងណា ការចេះចាប់យកក្រុមគោលដៅ ក៏ជាយុទ្ធសាស្ត្រមួយដើម្បីឈានទៅរកភាពជោគជ័យក្នុងអាជីវកម្មនេះផងដែរ។

ដោយសារការសិក្សានេះ មានលក្ខណៈតូច ក្នុងរបៀបជាករណីសិក្សា និងពុំបានផ្តោតលើគ្រប់ប្រភេទហាងកាហ្វេ យើងពុំអាចធ្វើការសន្និដ្ឋានបានច្បាស់លាស់ថា តើចំណូលចិត្តអតិថិជនកាហ្វេងាកទៅរកផលិតផលកាហ្វេក្នុងស្រុក ឬក្រៅស្រុកនោះទេ។ ទោះជាយ៉ាងណា តាមការស្ទង់មតិបុគ្គលិកបម្រើការងារក្នុងហាងកាហ្វេទាំងនោះ ប្រមាណ ៦៩.៥% នៃបុគ្គលិកទាំងនោះយល់ថា ប្រជាពលរដ្ឋកម្ពុជា គាំទ្រកាហ្វេក្នុងស្រុក ជាងកាហ្វេហាងម៉ាកផលិតផលបរទេស (មើលតារាងទី៣ខាងក្រោម)។

តារាងទី 3៖ ទស្សនៈបុគ្គលិកហាងកាហ្វេទៅលើដែលថា ប្រជាពលរដ្ឋកម្ពុជាចូលចិត្តកាហ្វេក្នុងស្រុកជាងកាហ្វេបរទេស

| | ចំនួន | ភាគរយ |
|---|---|---|
| មិនយល់ស្រប | 7 | 30.5 |
| យល់ស្រប | 16 | 69.5 |
| សរុប | 23 | 100.0 |

ពីព្រោះតាមបទពិសោធរបស់លោកដួង ដារា ដែលជាប្រធានក្រុមហ៊ុន មីស្ទ័រប្រ៊ូវកាហ្វេ បានធ្វើការគូសបញ្ជាក់ថា បច្ចុប្បន្ន កាហ្វេម៉ាកយីហោបរទេសប្រទេសមានការធ្លាក់ចុះ ហើយផលិតផលកាហ្វេក្នុងស្រុកចាប់ផ្តើមងើបឡើង ដោយសារតែប្រជាជនឥឡូវគាំទ្រផលិតផលកាហ្វេយីហោក្នុងស្រុកច្រើនជាង។ លោកដួង ដារា ក៏បានបន្ថែមថា ពីមុនគឺហាងកាហ្វេម៉ាកផលិតផលបរទេសបានទាក់ទាញអតិថិ

ជនបានច្រើន ដោយសារអ្នកក្នុងស្រុកមិនសូវដឹងពីរបៀបធ្វើអាជីវកម្មប្រភេទនេះ ប៉ុន្តែឥឡូវអាជីវកម្មកាហ្វេក្នុងស្រុក មានការយល់ដឹងច្រើនជាងមុន ជាពិសេសការជ្រើសរើសវត្ថុធាតុកាហ្វេ។

## ៣.២. បញ្ហាប្រឈម

ក្នុងចំណោមហាងកាហ្វេដែលបានចូលរួមក្នុងការសិក្សានេះ យើងសង្កេតឃើញថា មានហាងមួយចំនួនមានស្ថានភាពអាជីវកម្មរីកលូតលាស់ខ្លាំង ជាពិសេសហាងកាហ្វេប្រោនដែលមានសាខាអាជីវកម្មរហូតដល់២៥សាខា ទាំងនៅក្នុងរាជធានីភ្នំពេញ និងតាមបណ្ដាខេត្តសេដ្ឋកិច្ចនានាផងដែរ។ ស្ថិតក្នុងបរិបទនៃការប្រកួតប្រជែងនេះ ហាងកាហ្វេទាំងនោះក៏ជួបប្រទះនូវបញ្ហាប្រឈមមួយចំនួនផងដែរ។ លោកសុង ផេង ស្ថាបនិកស៊ីក្លូកាហ្វេបានធ្វើការគូសបញ្ជាក់ថា បញ្ហាតម្លៃ និងគុណភាពកាហ្វេជាកត្តាប្រឈមចម្បងជាងគេសម្រាប់អាជីវកម្មកាហ្វេក្នុងប្រទេសកម្ពុជា។ គាត់បានបន្ថែមថា មានហាងកាហ្វេក្នុងស្រុកមួយចំនួន ប្រកបអាជីវកម្មលក់កាហ្វេក្នុងតម្លៃថ្លៃជាងកាហ្វេម៉ាកផលិតផលបរទេសដែលកត្តានេះ បានធ្វើឱ្យពួកគេមានការពិបាកខ្លះៗក្នុងការឈរជើងប្រកួតប្រជែងក្នុងទីផ្សារបច្ចុប្បន្ន។ ជាមួយនឹងចំណុចនេះ ប្រមាណ១៥.៧% នៃបុគ្គលិកបម្រើការងារក្នុងហាងកាហ្វេក្នុងស្រុកទាំង៥ ក៏បានបញ្ចេញនូវទស្សនៈប្រហាក់ប្រហែលនេះដែរ។




រូបទី 1៖ បញ្ហាប្រឈមនៅក្នុងអាជីវកម្មកាហ្វេ (តាមទស្សនៈបុគ្គលិក)

បុគ្គលិកបម្រើការងារក្នុងហាងកាហ្វេទាំងនេះដដែល បានធ្វើការកត់សម្គាល់ថាក្រៅពីកត្តាគុណភាពនិងរសជាតិកាហ្វេ (រូបទី១ខាងលើ) អាជីវកម្មកាហ្វេក្នុងស្រុកនៅជួបប្រទះបញ្ហាប្រឈមផ្សេងទៀតផងដែរ ដែលក្នុងនោះបញ្ហាចម្បងជាងគេ គឺបញ្ហាដើមទុនអាជីវកម្ម (១៦.៨៥%) តម្លៃ និង

ការជួលទីតាំងប្រកបអាជីវកម្ម (១៥.៧៣%) សេវាកម្មនិងបអាកប្បកិរិយាបុគ្គលិក (១៤.៦១%) និងជម្រើសរសជាតិកាហ្វេ (១៣.៤៨%) ជាដើម។ បុគ្គលិកទាំងអស់បានផ្តល់តម្លៃទាបជាងគេទៅលើបរិយាកាស និងការតុបតែងក្នុងហាងកាហ្វេ (ប្រមាណ១០%)។ ដោយឡែកលោកគីម ហុង ដែលជាអ្នកគ្រប់គ្រងមួយរូបនៃហាងកាហ្វេប្រោនសាខា IFL ក៏បានគាំទ្រថា សម្រាប់ការប្រកួតប្រជែងជាមួយហាងកាហ្វេបរទេសគឺពាក់ព័ន្ធជាមួយនឹងជម្រើសនៃរសជាតិកាហ្វេ ដោយសារតែប្រជាជនយើងតែងតែចង់សាកចង់ដឹងពេលដំបូង តែប្រសិនបើគេមិនមានអ្វីថ្មីដែលល្អជាងយើងទេ នោះគេនឹងចាញ់យើង។

## ៣.៣. ឱកាសអាជីវកម្ម

បើទោះបីជាអាជីវកម្មកាហ្វេនេះជួបប្រទះនូវការប្រកួតប្រជែងខ្លាំង និងមានបញ្ហាប្រឈមមួយចំនួនក្តី ប៉ុន្តែឱកាសក្នុងការប្រកបអាជីវកម្មហាងកាហ្វេក្នុងប្រទេសកម្ពុជា នៅតែមានការលូតលាស់ជាបន្តទៅទៀត មិនថាជាហាងកាហ្វេម៉ាកផលិតផលបរទេស ឬក្នុងស្រុកនោះទេ ពីព្រោះអ្នកទទួលទានកាហ្វេក៏កើនឡើងកាន់តែច្រើន អ្នកបើកអាជីវកម្មហាងកាហ្វេថ្មីៗក៏មាន ហើយអ្នកបិទអាជីវកម្មទៅវិញក៏មានច្រើនដូចគ្នា។ ស្ថាបនិក និងអ្នកគ្រប់គ្រងហាងកាហ្វេទាំងនោះក៏បានគូសបញ្ជាក់ថា ឱកាសសម្រាប់អាជីវកម្មកាហ្វេគឺមាន ជាពិសេសអាជីវកម្មដែលមានផែនការច្បាស់លាស់ ហើយបានឈរជើងក្នុងវិស័យនេះចាប់ពី៣ឆ្នាំឡើងទៅ។

ដូចគ្នាដែរ បុគ្គលិកដែលបម្រើការងារក្នុងហាងកាហ្វេទាំងនេះ ក៏មានទស្សនៈប្រហាក់ប្រហែលនេះដោយ៨២.៦% នៃបុគ្គលិកទាំងនេះ យល់ថាទំនោរនិងនិន្នាការនៃការទទួលទានកាហ្វេក្នុងប្រទេសកម្ពុជានៅតែមានការកើនឡើង។ ម្យ៉ាងទៀត ប្រមាណ៧៤% នៃពួកគេ យល់ស្របដូចគ្នាថាឱកាសនៃអាជីវកម្មកាហ្វេក្នុងប្រទេសកម្ពុជានៅតែមានភាពល្អប្រសើរ (តារាងទី៤)។

តារាងទី 4៖ ទស្សនៈបុគ្គលិកហាងកាហ្វេទៅលើទំនោរនៃការទទួលទានកាហ្វេរបស់ប្រជាជនកម្ពុជា និងឱកាសសម្រាប់អាជីវកម្មកាហ្វេ

| ឱកាសសម្រាប់អាជីវកម្មកាហ្វេក្នុងប្រទេសកម្ពុជានៅមានភាពល្អប្រសើរ | | | ទំនោរនៃការទទួលទានកាហ្វេរបស់ប្រជាជនកម្ពុជានឹងបន្តកើនឡើង | | |
|---|---|---|---|---|---|
| | ចំនួន | ភាគរយ | | ចំនួន | ភាគរយ |
| មិនយល់ស្រប | 6 | 26.1 | មិនយល់ស្រប | 4 | 17.4 |
| យល់ស្រប | 17 | 73.9 | យល់ស្រប | 19 | 82.6 |
| សរុប | 23 | 100.0 | សរុប | 23 | 100.0 |

បន្ថែមពីលើការយល់ឃើញខាងលើ លទ្ធផលនៃការស្ទង់មតិបានបង្ហាញថា ដើម្បីបង្កើនឱកាសសម្រាប់អាជីវកម្មកាហ្វេរបស់ខ្លួន ហាងកាហ្វេទាំងនោះត្រូវផ្តោតលើចំណុចខ្លាំង ឬចំណុចដែលអាច

ទាក់ទាញអតិថិជន ដែលមាន កត្តាគុណភាពនិងរសជាតិកាហ្វេ តម្លៃ ការតុបតែងហាង សេវាកម្ម និង អាកប្បកិរិយាបុគ្គលិកជាដើម។ ប្រមាណ២៧% នៃបុគ្គលិកទាំងនោះយល់ថា ដើម្បីពង្រឹងឱកាសអាជីវកម្មកាហ្វេ យើងត្រូវផ្ដោតលើរសជាតិនិងគុណភាពជាចម្បង។ ម្យ៉ាងទៀត កត្តាគុណភាពនេះ អាចជាកត្តាចម្បងជាងគេបំផុត ដើម្បីពង្រឹងឱកាសក្នុងអាជីវកម្មកាហ្វេ។ ក្រៅពីកត្តាគុណភាព និងរសជាតិ ជម្រើសរសជាតិកាហ្វេ សេវាកម្មនិងអាកប្បកិរិយារបស់បុគ្គលិកបម្រើការងារក្នុងហាងកាហ្វេ ក៏ត្រូវបានពួកគេមើលឃើញថាជាចំណុចបង្កើតឱកាសសម្រាប់អាជីវកម្មនេះដូចគ្នា។ ដោយឡែក ប្រមាណ ៦% នៃបុគ្គលិកទាំងនោះយល់ថា ទីតាំងហាងកាហ្វេជាកត្តាដែលអាចបង្កើតឱកាសសម្រាប់អាជីវកម្មនេះបានទាបជាងគេ និង ប្រមាណ ៧.៦៩% យល់ថា បរិយាកាស និងការតុបតែងក្នុងហាង មិនមែនជាកត្តាកំណត់នូវឱកាសអាជីវកម្មទាំងស្រុងទេ (សូមមើលរូបទី២ខាងក្រោម)។




រូបទី 2៖ ទស្សនៈរបស់បុគ្គលិកហាងកាហ្វេអំពីចំណុចខ្លាំងនានាក្នុងអាជីវកម្មកាហ្វេ

ដោយឡែក បើផ្អែកលើទស្សនៈរបស់ស្ថាបនិក និងអ្នកគ្រប់គ្រងហាងកាហ្វេទាំង៥ខាងលើវិញ កត្តាចម្បង ដែលអាចធ្វើឱ្យអាជីវកម្មកាហ្វេអាចឈរជើងបានយ៉ាងរឹងមាំក្នុងបរិបទដែលមានការប្រកួតប្រជែងខ្លាំងបែបនេះគឺសេវាកម្ម។ ទាក់ទងនឹងចំណុចនេះ លោកសា ធុកា ដែលជាអ្នកគ្រប់គ្រងមួយរូបនៃសារមន្ទីរកាហ្វេ បានបញ្ជាក់ថា ទោះបីរសជាតិរបស់យើងមិនសូវជាឆ្ងាញ់ក៏ដោយ ប៉ុន្តែប្រសិនបើសេវាកម្មរបស់យើងល្អ បុគ្គលិករបស់យើងរស់រាយរាក់ទាក់ជាមួយភ្ញៀវ នោះភ្ញៀវមិនភ្លេចយើងនោះទេ គឺគេនឹងមកទទួលទានម្ដងហើយម្ដងទៀត។ ដូចនេះ ដើម្បីក្ដាប់យកឱកាសឱ្យបានកាន់តែច្រើន ហាងកាហ្វេទាំងឡាយត្រូវពង្រឹងសេវាកម្មមុនគេ ដោយចាំបាច់ត្រូវធ្វើយ៉ាងណាឱ្យបុគ្គលិករបស់ខ្លួនយល់ដឹងអំពីសេវាកម្មរបស់ហាង និងផ្ដល់សេវាកម្មដ៏ល្អដល់អតិថិជន។

## ៣.៤. ការបង្កើតការងារ

យើងសង្កេតឃើញថា ហាងកាហ្វេទាំង៥ដែលបានជ្រើសរើសក្នុងការស្រាវជ្រាវនេះ អាចបង្កើតការងារដល់យុវជនកម្ពុជាប្រមាណ១៤២កន្លែង ដែលក្នុងនោះមានបុគ្គលិកភេទស្រីចំនួន ៧២នាក់ ឬប្រមាណ ៥០.៧% ដោយមិនគិតលើសាខាផ្សេងទៀតរបស់ហាងកាហ្វេមួយចំនួននោះទេ។

តារាងទី 5៖ ឱកាសការងាររបស់អាជីវកម្មហាងកាហ្វេទាំង៥

| ឈ្មោះហាងកាហ្វេ | ចំនួនបុគ្គលិកសរុប (ស្រី) | ចំនួនសាខា |
|---|---|---|
| ស៊ីក្លូកាហ្វេ | ៣០ (១៥) | ៤ |
| កាហ្វេប្រោនសាខា IFL (Brown Coffee IFL) | ៣៥ (១២) | ២៥ |
| មីស្ទ័រប្រ៊ូវ កាហ្វេ (MisterBrew Coffee) | ៦០ (៣៦) | ៦ |
| សារមន្ទីរកាហ្វេ (The Museum Cafe) | ១២ (៦) | - |
| Neak Rady Café | ៥ (៣) | - |
| *សរុប* | ១៤២ (៧២) | |

លទ្ធផលនេះបង្ហាញថា អាជីវកម្មកាហ្វេបានផ្តល់ឱកាសការងារដល់បុគ្គលិកភេទស្រី ច្រើនជាងបុគ្គលិកភេទប្រុស ដោយឡែករបាយការណ៍ឆ្នាំ២០១៧ របស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យានិងនវានុវត្តន៍ក៏បានបង្ហាញផងដែរថា គ្រប់ប្រភេទអាជីវកម្មខ្នាតតូចនិងមធ្យមនៅកម្ពុជា បានផ្តល់ឱកាសការងារដល់ស្ត្រីច្រើនជាងបុរស ក៏ប៉ុន្តែស្ត្រីដែលជាម្ចាស់អាជីវកម្មខ្នាតតូចនិងមធ្យមនេះវិញ មានចំនួនតិចតួចខ្លាំង បើធៀបជាមួយបុរសដែលជាម្ចាស់អាជីវកម្ម (OpenDevelopment Cambodia, 2020)។

លទ្ធផលនេះក៏បានបង្ហាញផងដែរថា ឱកាសការងារដែលផ្តល់ដោយហាងកាហ្វេទាំងនេះ មិនត្រឹមតែសម្រាប់យុវជនកម្ពុជាដែលរស់នៅក្នុងទីក្រុងភ្នំពេញប៉ុណ្ណោះទេ ប៉ុន្តែក៏សម្រាប់យុវជនដែលមានដើមកំណើតពីខេត្តនានាផងដែរ។ លទ្ធផលបង្ហាញថា ៦៦.៦៧% នៃបុគ្គលិកដែលបម្រើការងារក្នុងហាងកាហ្វេទាំងប្រាំនេះ មានដើមកំណើតមកពីខេត្តនានាក្នុងប្រទេសកម្ពុជា និងជាង ៣៣% ទៀតជាអ្នកភ្នំពេញសុទ្ធសាធ (រូបទី៣ខាងក្រោម)។




*រូបភាពទី 3៖ ទិន្នន័យបញ្ជាក់ពីប្រភពនៃបុគ្គលិកបម្រើការងារនៅក្នុងហាងកាហ្វេទាំង៥*

ការដែលទទួលបានឱកាសការងារនេះ ក៏បានធ្វើឱ្យបុគ្គលិកស្ទើរតែទាំងអស់ (៩៥.៧%) អាចមានលទ្ធភាពក្នុងការបន្តការសិក្សាបន្ថែមទៀត បើទោះជាពួកគាត់ភាគច្រើន (៧០.៨%) ទទួលបានប្រាក់ចំណូលទាបជាង ២៥០ដុល្លាក៏ដោយចុះ (តារាងទី៦)។

តារាងទី 6៖ របាយប្រាក់បៀវត្សបុគ្គលិកបម្រើការងារក្នុងហាងកាហ្វេ

| ប្រាក់បៀវត្សប្រចាំខែ | ចំនួន | ភាគរយ |
|---|---|---|
| $150-$250 | 17 | 70.8 |
| $250-$300 | 4 | 16.7 |
| ច្រើនជាង $400 | 3 | 12.5 |
| សរុប | 24 | 100.0 |

ក្រៅពីឱកាសបន្តការសិក្សា ការងារជាបុគ្គលិកក្នុងហាងកាហ្វេទាំងនេះ ក៏បានចូលរួមចំណែកផងដែរក្នុងការពង្រឹងសេដ្ឋកិច្ចគ្រួសាររបស់ពួកគាត់។ ជាលទ្ធផល ៧៩.២% នៃបុគ្គលិកទាំងនោះបានធ្វើការគូសបញ្ជាក់ថា ស្ថានភាពសេដ្ឋកិច្ចគ្រួសាររបស់ពួកគាត់មានភាពល្អប្រសើរជាងមុន។

តារាងទី 7៖ ស្ថានភាពគ្រួសារបន្ទាប់ពីធ្វើការងារក្នុងហាងកាហ្វេ

| ស្ថានភាពសេដ្ឋកិច្ចគ្រួសារ | ចំនួន | ភាគរយ |
|---|---|---|
| ធ្លាក់ចុះបន្តិច | 1 | 4.2 |
| ពុំមានភាពប្រសើរឡើងទេ | 4 | 16.7 |
| ប្រសើរឡើងបន្តិចបន្តួច | 18 | 75.0 |

| | | |
|---|---|---|
| ប្រសើរឡើងច្រើន | 1 | 4.2 |
| សរុប | 24 | 100.0 |

តាមរយៈលទ្ធផលនេះ យើងអាចធ្វើការសន្និដ្ឋានបានថា អាជីវកម្មហាងកាហ្វេបានចូលរួមចំណែកយ៉ាងខ្លាំងក្នុងការបង្កើតការងារ ក៏ដូចជាពង្រឹងសេដ្ឋកិច្ចគ្រួសាររបស់និយោជិក និងបានចូលរួមក្នុងការជម្រុញនូវកំណើនសេដ្ឋកិច្ចជាតិផងដែរ។

# ៤. ការសន្និដ្ឋាន

យើងសង្កេតឃើញថា បើទោះបីជាស្ថិតក្នុងបរិបទនៃការប្រកួតប្រជែងខ្លាំងក្តី ឱកាសអាជីវកម្មសម្រាប់ហាងកាហ្វេម៉ាកក្នុងស្រុក នៅតែមានខ្ពស់នៅឡើយ។ ក្នុងបរិបទនេះ ហាងកាហ្វេក្នុងស្រុកក៏ជួបប្រទះនឹងបញ្ហាប្រឈមសំខាន់ៗដូចជា បញ្ហាកង្វះដើមទុនក្នុងការពង្រីកអាជីវកម្ម តម្លៃឈ្នួលទីតាំងហាង និងកិច្ចសន្យាជួល គុណភាពកាហ្វេ ជាដើម។ ជាមួយនឹងអាជីវកម្មនេះ យើងឃើញថា វាបានចូលរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់បុគ្គលិកបម្រើការងារក្នុងហាងបានមួយចំណែកធំ និងថែមទាំងជួយពង្រឹងកម្រិតជីវភាពគ្រួសាររបស់ពួកគេបានទៀតផងដែរ។ បន្ថែមពីលើនេះ វិស័យមួយនេះ ក៏បានចូលរួមផ្តល់ឱកាសក្នុងការបន្តការសិក្សាដល់បុគ្គលិកបម្រើការងារក្នុងហាងបានជាច្រើន ដែលនេះក៏ជាការរួមចំណែកមួយទៀតក្នុងការបណ្តុះបណ្តាលធនធានមនុស្សសម្រាប់ប្រទេសកម្ពុជាផងដែរ។

# ៥. យុទ្ធសាស្ត្រនិងអនុសាសន៍

ក្នុងបរិបទនៃការប្រកួតប្រជែងបែបនេះ ហាងកាហ្វេក្នុងស្រុកត្រូវមានយុទ្ធសាស្ត្រសមស្របដើម្បីអាចឈរជើងឱ្យបានរឹងមាំក្នុងអាជីវកម្មកាហ្វេ ទាំងការប្រកួតប្រជែងជាមួយនឹងម៉ាកកាហ្វេបរទេស ក៏ដូចជាហាងកាហ្វេម៉ាកក្នុងស្រុក។ តាមរយៈការសម្ភាសក្រុមគោលដៅដែលជាស្ថាបនិក អ្នកគ្រប់គ្រងហាងកាហ្វេទាំង៥ខាងលើ ក៏ដូចជាសិក្សាទៅលើយុទ្ធសាស្ត្រអាជីវកម្មមួយចំនួន យើងទទួលបាននូវអនុសាសន៍ ក៏ដូចជាសំណូមពរសំខាន់ៗមួយចំនួនទាំងសម្រាប់រាជរដ្ឋាភិបាល ក៏ដូចជាម្ចាស់អាជីវកម្មហាងកាហ្វេក្នុងស្រុក ក្នុងការបង្កើនឱកាសអាជីវកម្មរបស់ខ្លួនក្នុងបរិបទនៃការប្រកួតប្រជែងមួយនេះ។

## ក) អនុសាសន៍សម្រាប់រដ្ឋាភិបាល

### ○ ការផ្តល់ទុនសម្រាប់អាជីវកម្ម

យើងដឹងថា បញ្ហាប្រឈមដ៏ចម្បងមួយរបស់អាជីវកម្មកាហ្វេ ក៏ដូចជាអាជីវកម្មខ្នាតតូចនិងមធ្យមដ៏ទៃទៀតគឺថវិកាសម្រាប់ពង្រីក ឬជម្រុញភាពរីកចម្រើនក្នុងអាជីវកម្ម។ ជាមួយនឹងចំណុចនេះ

រាជរដ្ឋាភិបាលកម្ពុជា គួរពិចារណាផ្តល់នូវប្រាក់កម្ចីក្នុងអត្រាការប្រាក់ទាបសមរម្យជាងមុន ដើម្បីអ្នកប្រកបអាជីវកម្មហាងកាហ្វេនានា អាចមានលទ្ធភាពខ្ចី ទាំងសម្រាប់ការបើកអាជីវកម្មថ្មីថ្មោង ការពង្រឹង ក៏ដូចជាការពង្រីកអាជីវកម្មផងដែរ។

### ○ ពង្រឹងការលើកកម្ពស់អាជីវកម្មខ្នាតតូចនិងមធ្យម

ជាក់ស្តែង រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវយន្តការជាច្រើនរួចមកហើយក្នុងការជម្រុញការវិនិយោគលើវិស័យឧស្សាហកម្មខ្នាតតូចនិងមធ្យមនេះ។ ជាលទ្ធផល យើងសង្កេតឃើញថា ក្នុងប្រទេសកម្ពុជា មានការរីកចម្រើនខ្លាំងលើវិស័យមួយនេះ។ ដើម្បីជាការចូលរួមចំណែកបន្ថែមទៀត រាជរដ្ឋាភិបាលត្រូវគួរបង្កើតឱ្យមានយន្តការបន្ថែមទៀតដើម្បីគាំទ្រដល់អាជីវកម្មកាហ្វេ ក៏ដូចជាអាជីវកម្មខ្នាតតូច និងមធ្យម។ តាមបទពិសោធន៍របស់ប្រទេសនានា រាជរដ្ឋាភិបាលអាចផ្តល់ការគាំទ្រតាមរយៈការបង្កើតឱ្យមានកម្មវិធីបណ្តុះបណ្តាលសហគ្រិនភាព ការជួយជាដើមទុនសម្រាប់អាជីវកម្មបើកដំបូង (Start-Up Business) លើកទឹកចិត្តសហគ្រិនភាពក្នុងចំណោមនារីៗ ឬផ្តល់សេវាប្រឹក្សាកអាជីវកម្មជាដើម។ លើសពីនេះ ការសម្រួលបែបបទនីតិវិធីក្នុងការបើកអាជីវកម្ម ក៏អាចជាកត្តាជួយជម្រុញនូវការវិនិយោគបន្ថែមក្នុងវិស័យនេះផងដែរ។

## ខ) ចំពោះអាជីវកម្មហាងកាហ្វេក្នុងស្រុក

### ○ គុណភាពនិងរសជាតិ

តាមលទ្ធផលខាងលើ ចំណុចជោគជ័យធំបំផុតនៃអាជីវកម្មកាហ្វេគឺរសជាតិ និងគុណភាពកាហ្វេ ហើយចំពោះកាហ្វេម៉ាកផលិតផលបរទេស គឺគេមានចំណុចខ្លាំងមួយនេះ ដែលហាងកាហ្វេក្នុងស្រុកចាំបាច់ត្រូវរៀនតាម។ ជាទូទៅ អតិថិជនចូលចិត្តសាកល្បង និងស្វែងរករសជាតិកាហ្វេដែលបំពេញតាមតម្រូវការរបស់គេ ដូចនេះ ហាងកាហ្វេក្នុងស្រុកទាំងអស់ត្រូវធ្វើយ៉ាងណាពង្រឹង និងរក្សាគុណភាព និងរសជាតិកាហ្វេឱ្យបានជាប្រចាំ។ យើងដឹងថា ដើម្បីបានកាហ្វេដែលមានរសជាតិល្អឈ្ងុយឆ្ងាញ់ ចាំបាច់ត្រូវចេះជ្រើសរើសគ្រាប់កាហ្វេដែលមានគុណភាព និងមានបច្ចេកទេសក្នុងការឆុងឱ្យបានសមស្រប។

### ○ សេវាកម្មនិងបុគ្គលិក

សេវាកម្ម និងអាកប្បកិរិយារស់រាយរាក់ទាក់របស់បុគ្គលិកជាចំណុចសំខាន់មួយផងដែរក្នុងការទាក់ទាញចិត្តអតិថិជនឱ្យមកទទួលទានម្តងហើយម្តងទៀត។ ចំពោះហាងកាហ្វេបរទេស បុគ្គលិកត្រូវឆ្លងកាត់ការហ្វឹកហាត់ មានការណែនាំពីវិធីសាស្ត្រទំនាក់ទំនង និងបំពេញតម្រូវការអតិថិជន មុននឹង

អាចចាប់ផ្ដើមបំពេញការងារ។ នេះជាចំណុចខ្លាំងមួយរបស់គេ ក្នុងបរិបទនៃការប្រកួតប្រជែងក្នុងអាជីវកម្ម ដូចនេះ ម្ចាស់ហាងកាហ្វេក្នុងស្រុក ចាំបាច់ត្រូវផ្ដោតការយកចិត្តទុកដាក់លើសេវាកម្មរបស់ខ្លួន។

○ **ផ្ដោតលើតម្លៃ**

យើងដឹងហើយថា កម្ពុជាមានកម្រិតប្រាក់ចំណូលជាមធ្យមស្ថិតក្នុងកម្រិតទាបនៅឡើយបើធៀបជាមួយប្រទេសនានាក្នុងតំបន់។ ដូចនេះ ដើម្បីអាចប្រកួតប្រជែងបាននៅក្នុងទីផ្សារអាជីវកម្មកាហ្វេ ជាពិសេសជាមួយនឹងកាហ្វេបរទេស តម្លៃជាកត្តាកំណត់មួយផងដែរ។ ជាក់ស្ដែង តម្លៃនេះអាចនឹងក្លាយជាកត្តាកាន់តែសំខាន់ អាស្រ័យទៅលើទីតាំងហាងកាហ្វេ និងក្រុមអតិថិជនគោលដៅចម្បង។ ចំពោះអតិថិជនគោលដៅដែលជាសិស្សសាលា ឬនិស្សិត ពួកគេច្រើនជ្រើសរើសផលិតផលណាដែលមានតម្លៃសមរម្យបន្តិច ប៉ុន្តែបើអតិថិជនគោលដៅជាមន្ត្រីរាជការ ឬបុគ្គលិកក្រុមហ៊ុន តម្លៃមិនសូវជាបញ្ហាចោទសម្រាប់ពួកគេទេ។

○ **ជម្រើសផលិតផល**

តាមបទពិសោធន៍នានារបស់ស្ថាបនិក និងអ្នកគ្រប់គ្រងហាងកាហ្វេដែលបានចូលរួមក្នុងការសិក្សានេះ ពួកគេបានធ្វើការគូសបញ្ជាក់ថា អតិថិជនជាទូទៅចូលចិត្តអ្វីដែលថ្មី និងចង់ឱ្យយើងមានអ្វីដែលថ្មីសម្រាប់ពួកគេ ដូចនេះ ដើម្បីជោគជ័យក្នុងអាជីវកម្មនេះ ហាងកាហ្វេទាំងឡាយត្រូវរិះរកបង្កើតនូវជម្រើសផលិតផលឱ្យបានច្រើនបន្តិច ប៉ុន្តែពុំមានន័យថា ច្រើនខ្លាំងពេកនោះទេ។ ម្យ៉ាងទៀត មុននឹងបង្កើតនូវផលិតផលថ្មី ឬរសជាតិថ្មី ហាងកាហ្វេទាំងឡាយត្រូវមានការសិក្សាឱ្យបានច្បាស់ពីតម្រូវការ ប្រភេទរសជាតិ របស់អតិថិជនទៅតាមវ័យ និងការងារជាដើម។ ត្រង់ចំណុចនេះផងដែរ អ្នកគ្រប់គ្រងហាងកាហ្វេប្រោនសាខាIFL ក៏បានធ្វើការគូសបញ្ជាក់ដែរថា ចំណុចជោគជ័យមួយនៃហាងកាហ្វេរបស់គាត់គឺ គំនិតបង្កើតអ្វីៗដែលថ្មីជានិច្ច។

○ **ការតុបតែងលម្អ**

ការរៀបចំ និងការតុបតែងលម្អហាងដើម្បីឱ្យមានភាពទាក់ទាញ ក៏ជាកត្តាជោគជ័យមួយផងដែរ។ យើងសង្កេតឃើញថា យុវជនកម្ពុជាភាគច្រើនទទួលទានកាហ្វេក្នុងទីតាំងដែលមានផាសុកភាព មានម៉ាស៊ីនត្រជាក់ និងមានបរិយាកាសរ៉ូមែនទិកបន្ថែមទៀតកាន់តែប្រសើរ។ ចំណូលចិត្តនេះក៏អាស្រ័យទៅលើក្រុមមនុស្ស និងការងាររបស់អតិថិជនផងដែរ។ ការរៀបចំហាងកាហ្វេ អាចអាស្រ័យលើតម្រូវការអតិថិជនផងដែរដូចជា មានកន្លែងប្រជុំខ្នាតតូច និងតុពិសាកាហ្វេដែលមានឯកជនភាពជាដើម។ ការមានទីតាំងធំទូលាយ ងាយស្រួលក្នុងការចតយានយន្តរបស់អតិថិជន ជាចំណុចខ្លាំងបំផុតមួយផងដែរ ដោយសារទីក្រុងភ្នំពេញ តាមទីរួមខេត្ត ឬតំបន់ប្រជុំជនមួយចំនួន កំពុងជួបប្រទះនឹងបញ្ហាចរាចរណ៍។

## ០ ស្វែងយល់ពីទីផ្សារនិងចំណូលចិត្តអតិថិជនជាប្រចាំ

ហាងកាហ្វេទាំងឡាយត្រូវបង្កើតទម្លាប់ក្នុងការសិក្សា និងស្វែងយល់ពីការប្រែប្រួលនៃទីផ្សារ តម្រូវការ និងចំណង់ចំណូលចិត្តរបស់អតិថិជនជាប្រចាំ។ ពេលវេលាប្រែប្រួល ស្ថានភាពសង្គមប្រែប្រួល ឬបរិស្ថានជុំវិញប្រែប្រួល ក៏អាចធ្វើឱ្យអតិថិជនផ្លាស់ប្តូរចំណូលចិត្តផងដែរ។ ការប្រែប្រួលចំណូលចិត្តនេះ អាចទៅលើរសជាតិកាហ្វេ គុណភាព ឬបរិយាកាសក្នុងហាងកាហ្វេផ្ទាល់តែម្តង។ ឧទាហរណ៍ កាលពីប៉ុន្មានឆ្នាំមុន ការទទួលទានកាហ្វេច្រើនតែហាងតូចៗតាមផ្លូវ និងមានចាក់រ៉ឺឌីអូកំដរផងដែរ ប៉ុន្តែបច្ចុប្បន្ន ចំណូលចិត្តនេះបានប្រែប្រួលមកជាបរិយាកាសសមស្របសម្រាប់ការជជែកកំសាន្ត ឬបរិយាកាសដែលមានផ្តល់នូវសេវាអ៊ីនធើណេតមិនគិតថ្លៃ ឬមានបន្ទប់ជាលក្ខណៈឯកជនជាដើម។

# ឯកសារយោង


Allen Dodgson Tan. (2019, January 5). The Importance of SME Growth for Cambodia. Retrieved on September 02, 2020 from: https://www.khmertimeskh.com/50621102/the-importance-of-sme-growth-for-cambodia

Baily, P. (2008). 'Cambodian Small and Medium Sized: Enterprises: Constraints, Policies and Proposals for Their Development', in Lim, H. (ed.), SME in Asia and Globalization, ERIA Research Project Report 2007-5, pp.1-36.

Hin Pisei (2019, August 25). Ministry: SMEs vital to economy, but 95% not registered. Retrieved from: https://www.phnompenhpost.com/business/ministry-smes-vital-economy-95-not-registered.

Keskġn, Hidayet & Ġentürk, Canan & Sungur, Onur & Kġrġġ, Hakan. (2020). The Importance of SMEs in Developing Economies.

Khmertimeskh. (2020, 18 July). Cambodia announces new measures to support SMEs. Retrieved from: https://www.khmertimeskh.com/50746104/cambodia-announces-new-measures-to-support-smes/

OpenDevelopment Cambodia. (2020, June 3). Small and medium enterprises (SME). Retrieved from: https://opendevelopmentcambodia.net/topics/small-and-medium-enterprises-sme/#return-note-136409-14

Phnompenhpost. (2019, 5 March). Beyond coffee in Cambodia. Retrieved from: https://www.phnompenhpost.com/post-focus/beyond-coffee-cambodia

Phoung Vantha. (2019, July 28). Foreign brands dominate the coffee market in Cambodia. Retrieved from: https://cambodianess.com/article/foreign-brands-dominate-the-coffee-market-in-cambodia.

Samantha Fuentes. (2018, January 26). SMES AND FUNDING IN CAMBODIA: AN OVERVIEW. Retrieved on September 02, 2020 from: http://geeksincambodia.com/smes-and-funding-in-cambodia-an-overview/

Sok Chan. (2020, July 20). Coffee business finds a new way to survive. Retrieved from: https://www.khmertimeskh.com/50746429/coffee-business-finds-a-new-way-to-survive/.

Sok Chan. (2020, April 24). 'SME Development Policy' drafted for approval. Retrieved from: https://www.khmertimeskh.com/716393/sme-development-policy-drafted-for-approval/

The Nation. (2020, 20 August). Cambodia offers great opportunities for Thai bubble tea, coffee business. Retrieved from: https://english.cambodiadaily.com/business/cambodia-offers-great-opportunities-for-thai-bubble-tea-coffee-business-168168/

The World Bank Data. (2020). "GDP (current US$)-Cambodia". Retrieved 02th September 2020 from: https://data.worldbank.org/indicator/NY.GDP.MKTP.CD?locations=KH

Weggel & Oskar. (2006). "Cambodia in 2005: Year of Reassurance". Asian Survey. 46 (1): 158. doi:10.1525/as.2006.46.1.155.